**Double Criminality**

វិធាននេះ ជាលក្ខខណ្ឌ ដែលត្រូវបំពេញដើម្បីសម្រេចផ្តល់បត្យាប័ន ដែលសំដៅថា បទល្មើសត្រូវបានប្រព្រឹត្តដោយជនល្មើស មានចែងផ្តន្ទាទោសដោយច្បាប់នៃប្រទេសទាំងពីរ។

សន្ធិសញ្ញាគម្រូស្តីពីបត្យាប័នរបស់អង្គការសហប្រជាជាតិ បានចែងវិធាននេះក្នុងមាត្រា ២(១)។ វិធាននេះ ជាប្រធានបទនៃការពិភាក្សាក្តីគគុក ក្នុងដំណើរក្តីនៅមុខតុលាការអង់គ្លេស សម្រេចសំណើបត្យាប័ន Pinochet (*R. v. Bow Street Metropolitain*, Ex p. Pinichet Ugarte No. 3, 1999) ពីអង់គ្លេសទៅប្រទេសអេស្ប៉ាញ ដើម្បីទទួលការកាត់ទោសនៅទីនោះ។ បញ្ហាត្រង់ថា តើបទល្មើសទារុណកម្មប្រព្រឹត្តនៅក្នុងប្រទេស ឈីលី តាំងពីឆ្នាំ ១៩៧៣ ជាបទល្មើសទារុណកម្មក្រោមផ្នែក ១៣៤ នៃច្បាប់យុត្តិធម៌ព្រហ្មទណ្ឌឆ្នាំ ១៩៨៨ របស់ប្រទេសអង់គ្លេសដែរឬទេ? (Jonh P. Grant and J. Craig Barker, Encyclopedia Dictionary of International Law, 2009, p. 166)។

**ខ្លឹមសារបន្ថែម៖** មាត្រា ៥៦៩ លក្ខខណ្ឌនៃបត្យាប័នទាក់ទងនឹងអំពើ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧៖ បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់របស់រដ្ឋធ្វើសំណើផង និងតាមច្បាប់កម្ពុជាផង ទោះបីជា៖

- អំពើដែលជាបទល្មើសស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬ
- ឈ្មោះបទល្មើស ការប្រើបច្ចេកសព្ទ ឬនិយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ
- ធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើ ខុសគ្នាពីធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើ គឺជាការប្រព្រឹត្តិបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា ។